PSMA
27.06.2019

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ០៧ [illegible]

## សេចក្តីថ្លែងហេតុ
## ស្តីពី
## សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងព្រះរាជាណាចក្រកម្ពុជា និងសហភាពអារ៉ាប់អេមីរ៉ាត ស្តីពីការជំរុញនិងការការពារដោយទៅវិញទៅមកនៃវិនិយោគ

កិច្ចព្រមព្រៀងរវាងព្រះរាជាណាចក្រកម្ពុជា និងសហភាពអារ៉ាប់អេមីរ៉ាត ត្រូវបានចុះហត្ថលេខានៅរាជធានីភ្នំពេញ កាលពីថ្ងៃទី២៧ កក្កដា ឆ្នាំ២០១៧ ដោយឯកឧត្តម **សុខ ចិន្តាសោភា** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាអគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជាតំណាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងឯកឧត្តម **សាយអ៊ីហ្វ អាល់សាមស៊ី** (Saif Alshamsi) ឯកអគ្គរដ្ឋទូតសហភាពអារ៉ាប់អេមីរ៉ាតប្រចាំព្រះរាជាណាចក្រកម្ពុជា ដែលមានទីលំនៅ នៅទីក្រុងបាងកក ជាតំណាងសហភាពអារ៉ាប់អេមីរ៉ាត។

កិច្ចព្រមព្រៀងទ្វេភាគីរវាងព្រះរាជាណាចក្រកម្ពុជា និងសហភាពអារ៉ាប់អេមីរ៉ាត មានគោលបំណងជំរុញកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយពាក់ព័ន្ធទៅនឹងលំហូរទុនវិនិយោគទៅប្រទេសទាំងពីរ ជាពិសេសទាក់ទាញលំហូរវិនិយោគពីភាគីមិត្ត តាមរយៈការផ្តល់នូវការធានាសម្រាប់ការវិនិយោគ ការចូលមកស្នាក់នៅរបស់អ្នកវិនិយោគ និងបុគ្គលិករបស់ពួកគេផង និងកិច្ចការពារចំពោះអ្នកវិនិយោគនៃភាគីជាប់កិច្ចសន្យាម្ខាងលើទឹកដីនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត ដោយឈរលើមូលដ្ឋានស្មើភាព និងផ្តល់ផលប្រយោជន៍ឱ្យគ្នាទៅវិញទៅមក។ ព្រមជាមួយគ្នានេះ ភាគីជាប់កិច្ចសន្យាជាម្ចាស់ផ្ទះក៏មានភារកិច្ចផ្តល់នូវប្រព្រឹត្តកម្ម ត្រឹមត្រូវស្មើភាព ដើម្បីអ្នកវិនិយោគដែលកំពុងវិនិយោគលើទឹកដីរបស់ខ្លួនទទួលបាននូវការការពារ និងសន្តិសុខពេញលេញ ព្រមទាំងមិនធ្វើឱ្យខូចប្រយោជន៍ដល់ការគ្រប់គ្រង ការថែរក្សា ការប្រើប្រាស់ ការទទួលផល និងការចាត់ចែងការវិនិយោគដោយវិធានការមិនសមហេតុផល ឬរើសអើងពីភាគីណាមួយឡើយ។

ខ្លឹមសាររួមនៃកិច្ចព្រមព្រៀងបានបញ្ជាក់នូវចំណុចសំខាន់ៗ ដែលទាក់ទងទៅនឹងការធានារបស់ភាគីជាប់កិច្ចសន្យាម្ខាង ចំពោះការវិនិយោគលើទឹកដីរបស់ខ្លួន នូវប្រព្រឹត្តកម្មដោយស្មើភាព និងគ្មានការរើសអើងចំពោះអ្នកវិនិយោគសហភាពអារ៉ាប់អេមីរ៉ាត និងអ្នកវិនិយោគកម្ពុជា ការមិនធ្វើជាតូបនីយកម្ម ឬអស្សាមិករណ៍នូវទ្រព្យសម្បត្តិរបស់អ្នកវិនិយោគ ការផ្តល់ការអនុគ្រោះស្មើភាព លើកលែងតែជាប្រព្រឹត្តកម្មដែលភាគីជាប់កិច្ចសន្យាជាម្ចាស់ផ្ទះមានដោយឡែក ពាក់ព័ន្ធទៅនឹងកិច្ចព្រមព្រៀងសហព័ន្ធគយ តំបន់សេដ្ឋកិច្ចសេរី កិច្ចព្រមព្រៀងសហព័ន្ធហិរញ្ញវត្ថុ ឬកិច្ចព្រមព្រៀងអន្តរជាតិពាក់ព័ន្ធនឹងកិច្ចការសារពើពន្ធ។

ជាមួយគ្នានេះ កិច្ចព្រមព្រៀងបានបញ្ជាក់អំពីសំណងទាំងឡាយ ដែលភាគីជាប់កិច្ចសន្យាជាម្ចាស់ផ្ទះត្រូវសងជូនអ្នកវិនិយោគ ដែលបានទទួលរងការខូចខាតដោយករណីមួយចំនួន តាមរយៈការទូទាត់ជារូបិយវត្ថុ

ដែលអាចប្តូរបានដោយសេរីតាមតម្លៃទីផ្សារ និងការផ្ទេរចេញទៅក្រៅប្រទេស តាមសំណូមពររបស់អ្នកវិនិយោគ នូវមូលធន ដែលបានមកពីផលចំណេញលើការវិនិយោគ។ កិច្ចព្រមព្រៀងក៏បានបញ្ជាក់ផងដែរ នូវវិធានការសម្រាប់ដោះស្រាយវិវាទវិនិយោគរវាងអ្នកវិនិយោគនៃភាគីជាប់កិច្ចសន្យាម្ខាង ជាមួយភាគីជាប់កិច្ចសន្យាជាម្ចាស់ផ្ទះ និងវិវាទរវាងភាគីជាប់កិច្ចសន្យាទាំងពីរ ស្របទៅតាមបែបបទ និងស្តង់ដារដែលធ្លាប់បានអនុវត្តកន្លងមក។

កិច្ចព្រមព្រៀងនេះមាន ១៥មាត្រា ហើយមានសុពលភាពរយៈពេល ១០ (ដប់) ឆ្នាំ គិតចាប់ពីថ្ងៃចូលជាធរមាន នៅក្រោយពេលភាគីទាំងពីរជូនដំណឹងតាមផ្លូវទូត អំពីការបានបំពេញរួចរាល់នូវនីតិវិធីផ្ទៃក្នុងតម្រូវដោយរដ្ឋធម្មនុញ្ញរបស់ភាគីនីមួយៗសម្រាប់ការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ។

ជារួមខ្លឹមសារនៃកិច្ចព្រមព្រៀងនេះ មានលំនាំប្រហាក់ប្រហែលទៅនឹងបណ្តាកិច្ចព្រមព្រៀងផ្សេងៗទៀត ស្តីពីការជំរុញនិងការការពារទៅវិញទៅមកនៃវិនិយោគ ដែលព្រះរាជាណាចក្រកម្ពុជាយើង ធ្លាប់បានចុះហត្ថលេខាជាមួយបណ្តាប្រទេសចំនួន២៧ កន្លងមក។

សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងព្រះរាជាណាចក្រកម្ពុជា និងសហភាពអារ៉ាប់អេមីរ៉ែត ស្តីពីការជំរុញនិងការការពារទៅវិញទៅមកនៃវិនិយោគ ត្រូវបានគណៈរដ្ឋមន្ត្រីសម្រេចយល់ព្រមក្នុងសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នាថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៩ ដើម្បីបញ្ជូនទៅសុំការអនុម័តពីស្ថាប័ននីតិប្បញ្ញត្តិដែលរួមមាន ៣មាត្រា។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមរដ្ឋសភាមេត្តាពិនិត្យ និងអនុម័តសេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងព្រះរាជាណាចក្រកម្ពុជា និងសហភាពអារ៉ាប់អេមីរ៉ែត ស្តីពីការជំរុញនិងការការពារទៅវិញទៅមកនៃវិនិយោគ ជាការប្រញាប់ ដោយក្តីអនុគ្រោះ។

ថ្ងៃអង្គារ ១ កើត ខែចេត្រ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ៥ ខែមេសា ឆ្នាំ២០១៩

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

# សេចក្តីព្រាង

# ច្បាប់

## ស្តីពី

## ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងព្រះរាជាណាចក្រកម្ពុជា និងសហភាពអារ៉ាប់អេមីរ៉ែត ស្តីពីការជំរុញនិងការការពារទៅវិញទៅមកនៃវិនិយោគ

**មាត្រា១.-**

អនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងព្រះរាជាណាចក្រកម្ពុជា និងសហភាពអារ៉ាប់អេមីរ៉ែត ស្តីពីការជំរុញនិងការការពារទៅវិញទៅមកនៃវិនិយោគ ដែលបានចុះហត្ថលេខានៅរាជធានីភ្នំពេញ នៃព្រះរាជាណាចក្រកម្ពុជា នាថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៧ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ។

**មាត្រា៣.-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។៚

ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
អនុម័តនៅថ្ងៃទី ខែ ឆ្នាំ២០១៩
នាសម័យប្រជុំរដ្ឋសភាលើកទី នីតិកាលទី៦។
ថ្ងៃ ខែ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ ២០១៩

**ប្រធានរដ្ឋសភា**

**សម្តេចអគ្គមហាពញាចក្រី ហេង សំរិន**